អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

អគ្គនាយកដ្ឋានស្រាវជ្រាវ

នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

**មាតិកា៖**

- ការមកដល់នៃភ្ញៀវទេសចរអន្តរជាតិនៅកម្ពុជាត្រូវបានរំពឹងថានឹងបន្តធ្លាក់ចុះ ពី ៦០% ទៅ ៧០% សម្រាប់ឆ្នាំ ២០២១
- សកម្មភាពអាជីវកម្មថ្មីនៅតែបន្តមាន បើទោះជាកម្ពុជាកំពុងប្រឈមនឹងការរីករាលដាលខ្លាំងនៃជំងឺកូវីដ-១៩
- ការនាំចេញទំនិញរបស់ប្រទេសកម្ពុជាទៅកាន់ទីផ្សារប្រទេសកូរ៉េខាងត្បូងនៅតែបន្តរក្សាកំណើន គិតត្រឹមត្រីមាសទី១ ឆ្នាំ២០២១
- ការចំណាយលើអត្ថប្រយោជន៍សង្គមប្រចាំខែកុម្ភៈ ឆ្នាំ២០២១
- ការនាំចេញរបស់ជប៉ុនកើនឡើងពីរខ្ទង់ ជាលើកដំបូងចាប់តាំងពីឆ្នាំ២០១៨
- គណៈកម្មាធិការអចិន្ត្រៃយ៍រួម លើពាណិជ្ជកម្មឧស្សាហកម្ម និងធនាគារ (JSCCIB) បានព្យាករណ៍ថា ផលិតផលក្នុងស្រុកប្រទេសថៃ នឹងធ្លាក់ចុះពី០,៥% ទៅ ១%
- សេដ្ឋកិច្ចរបស់អាមេរិករំពឹងថា នឹងមានកំណើនខ្លាំង ប៉ុន្តែកំណើនការងារមានភាពយឺតយ៉ាវ
- វិបត្តិជំងឺកូវីដ-១៩ នឹងបន្សល់ទុកនូវស្លាកស្នាមយ៉ាងជ្រាលជ្រៅនៅក្នុងសេដ្ឋកិច្ចពិភពលោក ទោះបីជាសេដ្ឋកិច្ចងើបឡើងវិញក៏ដោយ


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមវរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា

ចងក្រង និងបូកសរុបដោយ

- ធីម ប៊ុនធឿន ប្រធានការិយាល័យវិភាគចំណូល-ចំណាយ

# ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

## ការមកដល់នៃភ្ញៀវទេសចរអន្តរជាតិនៅកម្ពុជា ត្រូវបានរំពឹងថានឹងបន្តធ្លាក់ចុះពី ៦០% ទៅ ៧០% សម្រាប់ឆ្នាំ២០២១



*ប្រភព៖ Khmer Times ២០២១*

យោងតាមរបាយការណ៍របស់ក្រសួងទេសចរណ៍ បានបង្ហាញថា សម្រាប់ឆ្នាំ២០២១នេះ វិស័យទេសចរណ៍កម្ពុជា នឹងបន្តធ្លាក់ចុះពី ៦០% ទៅ ៧០% បន្ថែមទៀត ដោយសារតែការរីករាលដាលនៃជំងឺកូវីដ-១៩ នៅតែបន្ត។ ក្នុងនោះដែរ ក្នុងឆ្នាំ២០២០ ប្រទេសកម្ពុជាទទួលបានភ្ញៀវទេសចរអន្តរជាតិត្រឹមតែ១,៣១លាននាក់ ធ្លាក់ចុះប្រមាណជា ៨០% ធៀបនឹងឆ្នាំ២០១៩ ដែលមានភ្ញៀវទេសចរអន្តរជាតិសរុប ៦,៦១លាននាក់។

ទន្ទឹមនេះដែរ បើពិនិត្យមើលលើចំណូលបានពីវិស័យទេសចរណ៍ក្នុងឆ្នាំ២០២០វិញឃើញថា មានការធ្លាក់ចុះប្រមាណជា ៧៩% មកត្រឹម ១,០២ប៊ីលានដុល្លារ ខណៈដែលឆ្នាំ២០១៩ វិស័យនេះទទួលបានចំណូលសរុបដល់ទៅ ៤,៩២ប៊ីលានដុល្លារ។

សម្រាប់ឆ្នាំ២០២០ វិស័យទេសចរណ៍ បានរួមចំណែកត្រឹមតែ ៣% ប៉ុណ្ណោះទៅក្នុងផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) ធៀបនឹងឆ្នាំ២០១៩ វិស័យនេះបានរួមចំណែក ១២% នៃផ.ស.ស.៕ *ដោយ ជា សិរីរតន៍*

*ប្រភព៖ Khmer Times, ចេញផ្សាយ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១*

## សកម្មភាពអាជីវកម្មថ្មីនៅតែបន្តមាន បើទោះជា កម្ពុជាកំពុងប្រឈមនឹងការរីករាលដាលខ្លាំងនៃជំងឺកូវីដ-១៩



*ប្រភព៖ Khmer Times ២០២១, រូបភាព៖ Chor Sokunthea*

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នៅតែបន្តផ្តល់ការអនុម័តទៅលើគម្រោងវិនិយោគថ្មី បើទោះបីជាវិបត្តិជំងឺកូវីដ-១៩ នៅតែបន្ត រួមទាំងការដាក់ចេញនូវបម្រាមគោចរ និងវិធានការបិទខ្ទប់នាពេលបច្ចុប្បន្ននេះក៏ដោយ ដែលនេះបង្ហាញពីសញ្ញាសុទិដ្ឋិនិយមមួយសម្រាប់

កម្ពុជានៅពេលដែលកម្ពុជាឆ្លងផុតពីបញ្ហាប្រឈមថ្មីៗ នេះ និង បន្ទាប់ពីវិបត្តិកូវីដ-១៩។

រោងចក្រថ្មីចំនួន ០៥ ត្រូវបានអនុម័ត នៅក្នុងខែមេសា ដែលមានតម្លៃសរុប ២០,៥លានដុល្លារ និងអាចបង្កើត ការងារសរុបចំនួន ៣ ៧០០ការងារ ដែលក្នុងនោះ មានដូចជា៖ Vanzel Printing & Packaging(Cambodia) Garments Co Ltd (គម្រោងតម្លៃ ២,១លាន ដុល្លារ បង្កើតការងារ ៣០០ការងារ), Windmill-FY (Cambodia) Garments Co Ltd(គម្រោងតម្លៃ ២,៥ លានដុល្លារ បង្កើតការងារ ៨៤៨ការងារ), Spark bags (Cambodia) Co Ltd (គម្រោងតម្លៃ ៣,៣ លានដុល្លារ បង្កើតការងារ ៧១៨ការងារ), McBag Co Ltd (គម្រោងតម្លៃ ៣,៥លានដុល្លារ បង្កើតការងារ ៨១៨ ការងារ) និង Cambodian Qi Ming Xing Jia Ju Yong Pin Co Ltd (គម្រោងតម្លៃ ៩,១លានដុល្លារ បង្កើតការងារ ១ ០២២ការងារ)។

ទន្ទឹមនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានលើក ឡើងថា កម្ពុជាបានអនុម័តនូវគម្រោងសាងសង់ ដែល មានតម្លៃ ៧,៧ប៊ីលានដុល្លារ នៅឆ្នាំ២០២០ ដែលនេះ បង្ហាញពីសុទិដ្ឋិនិយមសម្រាប់វិស័យសំណង់ សម្រាប់ រយៈពេល ០២ឆ្នាំខាងមុខ។ ក្រសួងបានព្យាករណ៍ថា វិស័យសំណង់ នឹងមានកំណើន ៩% នៅឆ្នាំ២០២១ និង ៧,៨% នៅឆ្នាំ២០២២។ *ដោយ ជា សិរីរតន៍*

*ប្រភព៖ Khmer Tiimes, ចេញផ្សាយ ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១*

## ការនាំចេញទំនិញរបស់ប្រទេសកម្ពុជាទៅកាន់ទីផ្សារ ប្រទេសកូរ៉េខាងត្បូងនៅតែបន្តរក្សាកំណើន គិតត្រឹម ត្រីមាសទី១ ឆ្នាំ២០២១



*ប្រភព៖ postkhmer 2021, រូបភាព៖ ហេង ជីវ័ន (កំពង់ផែក្រុង ព្រះសីហនុ)*

យោងតាមទិន្នន័យពីសមាគមពាណិជ្ជកម្មអន្តរជាតិកូរ៉េ (Kita)បានបង្ហាញថា នៅក្នុងត្រីមាសទី១ ឆ្នាំ២០២១ ការនាំចេញទំនិញពីប្រទេសកម្ពុជាទៅកាន់ទីផ្សារប្រទេស កូរ៉េខាងត្បូងមានតម្លៃ ៩៩,០៧លានដុល្លារ កើនឡើង ៥,៦% ធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំមុន។ ដោយឡែក ការនាំចូលទំនិញពីប្រទេសកូរ៉េខាងត្បូងមកប្រទេស កម្ពុជាវិញ គឺមានការធ្លាក់ចុះប្រមាណ ០,៦% ពីចំនួន ១៤៧,៨លានដុល្លារ មកនៅត្រឹម១៤៦,៩លានដុល្លារ។

ជារួម ទំហំពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសទាំងពីរ នៅ ក្នុងត្រីមាសទី១ឆ្នាំ២០២១នេះ មានតម្លៃសរុប ២៤៦លាន ដុល្លារ កើនឡើង ១,៧៨% ធៀបនឹងរយៈពេលដូចគ្នា កាលពីឆ្នាំមុន ដែលមានចំនួន ២៤១,៧លានដុល្លារ។

យោងតាម លោក ហុង វណ្ណៈ អ្នកស្រាវជ្រាវសេដ្ឋកិច្ចអន្តរជាតិ នៃវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិ នៃកម្ពុជា បានលើកឡើងថា ទោះបីស្ថិតនៅក្នុងស្ថានភាពបែបណាក៏ដោយ ក៏ទំហំពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងប្រទេសកូរ៉េខាងត្បូងនៅតែបង្ហាញភាពវិជ្ជមាន។ ការណ៍នេះគឺដោយសារប្រទេសទាំងពីរបានបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី (FTA) ហើយឧស្សាហកម្មផលិតនៅប្រទេសកម្ពុជា មានផលិតផលកាន់តែច្រើន និងមានគុណភាពស្របតាមស្តង់ដារនៃការចង់បានរបស់អ្នកបញ្ជាទិញ។

ទំនិញសំខាន់ៗដែលប្រទេសកម្ពុជានាំចេញទៅកាន់ប្រទេសកូរ៉េខាងត្បូង រួមមាន៖ សម្លៀកបំពាក់ ស្បែកជើង ផលិតផលធ្វើដំណើរ កៅស៊ូ គ្រឿងបន្លាស់អេឡិចត្រូនិច ភេសជ្ជៈ ថ្នាំពេទ្យ និងផលិតផលប្លាស្ទិក។

កំណើននៃការនាំចេញនេះ នឹងមានភាពប្រែប្រួលនៅក្នុងត្រីមាសទី២ ខណៈការរីករាលដាលនៃជំងឺកូវីដ-១៩ នៃព្រឹត្តិការណ៍សហគមន៍២០ កុម្ភៈ កំពុងធ្វើឱ្យរោងចក្រជាច្រើននៅក្នុងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ ត្រូវផ្អាកសកម្មភាព ដើម្បីចូលរួមសហការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺឆ្លងស្របតាមវិធានការរបស់រាជរដ្ឋាភិបាល នេះបើយោងតាមលោក លឹម ហេង អនុប្រធានសភាពាណិជ្ជកម្ម។

គួរបញ្ជាក់ផងដែរ ប្រទេសកម្ពុជា និងប្រទេសកូរ៉េខាងត្បូង បានបញ្ចប់ការចរចាជាមួយគ្នាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី កាលពីដើមខែកុម្ភៈ ដោយភាគីទាំងពីរគ្រោងនឹងចុះហត្ថលេខាជាមួយគ្នានៅក្នុងអំឡុងខែមិថុនា ឆ្នាំ២០២១នេះ៕ *ដោយ សេន ចន្ទ*

*ប្រភព៖ postkhmer.com, ចេញផ្សាយថ្ងៃទី១៨ ខែមេសា ឆ្នាំ ២០២១*

## តារាងប្រចាំសប្តាហ៍៖ ការចំណាយលើអត្ថប្រយោជន៍សង្គមប្រចាំខែកុម្ភៈ ឆ្នាំ២០២១

ទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា បង្ហាញថា៖ នៅក្នុងខែកុម្ភៈ ឆ្នាំ២០២១ រដ្ឋបាលថ្នាក់ជាតិ បានចំណាយលើអត្ថប្រយោជន៍សង្គម មានទំហំទឹកប្រាក់សរុបចំនួន ១១៥,០២ប៊ីលានរៀល ដែលមានកំណើនប្រមាណជា ១១,៤% បើធៀបនឹងខែមករា។

កំណើននៃការចំណាយនេះ ដោយសារតែរាជរដ្ឋាភិបាល បានប្រើប្រាស់ថវិកាដើម្បីជួយដោះស្រាយនូវផលប៉ះពាល់នៃការរីករាលដាលជំងឺកូវីដ-១៩ ទៅលើផ្នែកសុខាភិបាលសង្គម និងសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា។

ជាក់ស្តែង ការចំណាយលើការឧបត្ថម្ភអង្គភាពដែលមានលក្ខណៈសង្គម និងវប្បធម៌ មានទំហំទឹកប្រាក់ ៤,៨៣ ប៊ីលានរៀល នៅក្នុងខែកុម្ភៈ ឆ្នាំ២០២១ ដែលមានកំណើនយ៉ាងខ្លាំងរហូតដល់ ៤៩,៥% បើធៀបនឹងខែមុន។

ស្របពេលនោះដែរ ការចំណាយលើអត្ថប្រយោជន៍សន្តិសុខសង្គមមានទឹកប្រាក់ចំនួន ១០១,០៤ប៊ីលានរៀល នៅក្នុងខែកុម្ភៈឆ្នាំ២០២១ ដែលមានកំណើនប្រមាណជា ១១,៥% ផងដែរ។

តែទោះបីយ៉ាងក៏ដោយ ការចំណាយលើជំនួយសង្គមដល់ប្រជាពលរដ្ឋ មានទឹកប្រាក់ចំនួន ៩,១៥ប៊ីលានរៀល ប៉ុណ្ណោះ ក្នុងខែកុម្ភៈ ឆ្នាំ២០២១ ដែលមានការធ្លាក់ចុះប្រមាណជា ២,១% បើធៀបនឹងខែមុន។

ដោយឡែក ការចំណាយអត្ថប្រយោជន៍សង្គមផ្សេងៗទៀត មិនមានទេ នៅខែកុម្ភៈឆ្នាំ២០២១នេះ៕

*ដោយ មិត្ត ចន្ទី*

| ការចំណាយឆ្នាំ២០២១ (គិតជាប៊ីលានរៀល) | មករា | កុម្ភៈ | កំណើន/ថយ(%) |
|---|---|---|---|
| អត្ថប្រយោជន៍សង្គម | 103.21 | 115.02 | 11.4% |
| អត្ថប្រយោជន៍សន្តិសុខសង្គម | 90.63 | 101.04 | 11.5% |
| ជំនួយសង្គមដល់ប្រជាពលរដ្ឋ | 9.35 | 9.15 | -2.1% |
| ឧបត្ថម្ភអង្គភាពដែលមានលក្ខណៈសង្គម និងវប្បធម៌ | 3.23 | 4.83 | 49.5% |
| អត្ថប្រយោជន៍សង្គមផ្សេងៗទៀត | - | - | 0.0% |

*ប្រភព៖តារាងប្រតិបត្តិការហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ការនាំចេញរបស់ជប៉ុនកើនឡើងពីរខ្ទង់ ជាលើកដំបូងចាប់តាំងពីឆ្នាំ២០១៨



*ប្រភព៖ The Japan times, 2021/ Bloomberg*

ការនាំចេញរបស់ជប៉ុនក្នុងខែមីនាឆ្នាំ២០២១ មានការកើនឡើងពីរខ្ទង់ជាលើកដំបូងនៅក្នុងរយៈពេលបីឆ្នាំកន្លងមក ដែលបានបង្ហាញពីការងើបឡើងវិញ នៃពាណិជ្ជកម្មពិភពលោក។

យោងតាមក្រសួងហិរញ្ញវត្ថុរបស់ជប៉ុនបានបង្ហាញថា ក្នុងខែមិនា ការនាំចេញទៅក្រៅប្រទេសបានកើនឡើង ១៦,១% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ខ្ពស់ជាងការព្យាករណ៍ដែលមានត្រឹម ១១,៤%។ ចំណែកឯការនាំចូលវិញបានកើនឡើង ៥,៧% ធៀបនឹងឆ្នាំមុនដែលការព្យាករណ៍មានកំណើនត្រឹម ៤,៧%។

ទន្ទឹមនឹងនេះ នៅក្នុងត្រីមាសទី១ ឆ្នាំ២០២១ ការនាំចេញកើនឡើង ៦% និងការនាំចូលកើនឡើង ១,៩% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ។

ខណៈពេលដែលតួលេខខ្ពស់ជាងការរំពឹងទុកដោយសារការប្រៀបធៀបជាមួយនឹងតួលេខកាលពីឆ្នាំ២០២០ នៅពេលមានជំងឺឆ្លងកំពុងបំផ្លាញពាណិជ្ជកម្មពិភពលោកនោះ ការគណនាដោយកែតម្រូវតាមរដូវកាល (seasonal adjustment) បានបង្ហាញថា ការនាំចេញនៅតែមានកំណើនខ្ពស់ក្នុងរយៈពេលបីឆ្នាំចុងក្រោយដដែល។ ដោយឡែកការនាំចេញប្រចាំខែកើនឡើង៤,៣%។

ប្រភេទទំនិញនៃការនាំចេញរបស់ជប៉ុនរួមមាន៖ រថយន្ត ផ្លាស្ទិក វត្ថុធាតុដើមឧបករណ៍អេឡិចត្រូនិក(semi-conductors) និងឧបករណ៍ផលិតបន្ទះឈីប (Chip-making equipment) ដែលមានការកើនឡើងខ្លាំងបំផុតចាប់តាំងពីខែវិច្ឆិកាឆ្នាំ២០១៧។

ការកើនឡើងនូវការនាំចេញបានជួយគាំទ្រដល់សេដ្ឋកិច្ចប្រទេសជប៉ុន ក្នុងអំឡុងពេលការចាក់វ៉ាក់សាំងត្រូវបានពន្យារពេល និងការលេចឡើងនូវរលកទី៤ នៃការឆ្លងមេរោគ ដែលកំពុងជះឥទ្ធិពលខ្លាំងលើសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក ជាមួយការសង្ស័យថាអាចនឹងមានការប្រកាសដាក់ប្រទេសក្នុងគ្រាអាសន្ននៅក្នុងទីក្រុងតូក្យូ ដែលការណ៍នេះនឹងទាញសេដ្ឋកិច្ចឱ្យធ្លាក់ចុះ។

ការនាំចេញរបស់ជប៉ុនទៅកាន់ប្រទេសចិនក្នុងខែមីនាបានកើនឡើង ៣៧,២% ធៀបនឹងឆ្នាំមុន។ បន្ថែមពីនេះ ការនាំចេញទៅកាន់សហរដ្ឋអាមេរិកកើនឡើង៤,៩% និងការនាំចេញទៅកាន់សហភាពអឺរ៉ុបកើនឡើង ១២,៨% ដែលជាកំណើនខ្ពស់បំផុតក្នុងរយៈពេលជិតបីឆ្នាំនេះ។

តុល្យភាពពាណិជ្ជកម្មរបស់ជប៉ុនមានចំនួន ៦៦៣,៧ ប៊ីលានយ៉េន ខ្ពស់ជាងការព្យាករណ៍របស់ក្រុមអ្នកវិភាគដែលបានរំពឹងថានឹងមានអតិរេកចំនួន ៤៩៣,២ ប៊ីលានយ៉េន៕ *ដោយ មុំ ចិន្តា*

*ប្រភព៖ The Japan times, ចេញផ្សាយថ្ងៃទី១៩ ខែមេសា ឆ្នាំ ២០២១*

## គណៈកម្មាធិការអចិន្ត្រៃយ៍រួមលើពាណិជ្ជកម្ម ឧស្សាហកម្ម និងធនាគារ (JSCCIB) បានព្យាការណ៍ថា ផលិតផលក្នុងស្រុកប្រទេសថៃ នឹងធ្លាក់ចុះពី ០,៥% ទៅ ១%

គណៈកម្មាធិការអចិន្ត្រៃយ៍រួមលើពាណិជ្ជកម្ម ឧស្សាហកម្ម និងធនាគារ (JSCCIB) ព្យាករណ៍ថា ផលិតផលក្នុងស្រុកសរុប(ផ.ស.ស.) នៃប្រទេសថៃនឹងមានការធ្លាក់ចុះពី ០,៥% ទៅ ១% ប្រសិនបើរាជរដ្ឋាភិបាលអាចគ្រប់គ្រងរលកកូវីដ-១៩ថ្មីរបស់ខ្លួនបាននៅក្នុងខែមេសា ឬខែឧសភាខាងមុខនេះ។

JSCCIB នឹងបន្ទាបការព្យាករណ៍កំណើនសេដ្ឋកិច្ចរបស់ខ្លួននៅក្នុងឆ្នាំ២០២១ ដោយសារការធ្លាក់ចុះនៃចំណាយសារធារណៈ។ ដោយឡែក អត្រានៃជំងឺឆ្លងក្នុងមួយថ្ងៃមានរហូតដល់ជាង ១ ០០០នាក់ ក៏ជះឥទ្ធិពលដល់ដំណើរការនៃសេដ្ឋកិច្ចផងដែរ។

កាលពីពេលថ្មីៗនេះ JSCCIB បានប៉ាន់ស្មានថា ផ.ស.ស. របស់ប្រទេសថៃនឹងកើនឡើងពី ១,៥% ទៅ ៣,៥% នៅក្នុងឆ្នាំ២០២១នេះ ជាមួយនឹងការនាំចេញកើនឡើង ៣% ទៅ ៥% និងអត្រាអតិផរណា ០,៨% ទៅ ១% ដែលការព្យាករណ៍នេះ គឺផ្អែកមួយផ្នែកទៅលើកញ្ចប់ចំណាយសម្រាប់ជំរុញកំណើនសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល។

យោងតាមលោក Kriengkrai Thiennukul អនុប្រធានសហព័ន្ធឧស្សាហកម្មថៃ(FTI)បានលើកឡើងថា រលកទី៣ នៃជំងឺឆ្លងកូវីដ-១៩ ពិតជាជះឥទ្ធិពលខ្លាំងមកលើអាជីវកម្មជាច្រើន ដែលមិនអាចបើកដំណើរការបាន ហើយបានប៉ះពាល់ដល់ការបញ្ជាទិញ និងការងារផងដែរ ដោយប្រជាជនទាំងអស់ត្រូវធ្វើការពីផ្ទះ។

បន្ថែមពីនេះ សហព័ន្ធឧស្សាហកម្មថៃ( FTI ) រំពឹងថារាជរដ្ឋាភិបាល នឹងបន្តការចាក់វ៉ាក់សាំងដល់ប្រជាជនក្នុងអំឡុងត្រីមាសទី៣ និងគ្របដណ្តប់បាន ៧០% នៃប្រជាជនថៃទាំងមូល។

ភាពជោគជ័យក្នុងការដោះស្រាយវឌ្ឍនភាព នៃដំណើរការចាក់វ៉ាក់សាំង នឹងក្លាយជាផ្នែកមួយដ៏សំខាន់នៃការស្តារសេដ្ឋកិច្ច និងការចាប់ផ្តើមសកម្មភាពអាជីវកម្មឡើងវិញ ព្រមទាំងបង្កើតទំនុកចិត្តចំពោះភ្ញៀវទេសចរបរទេស។ ដោយឡែក សហគ្រាសធុនតូច និងមធ្យមជាច្រើន ដែលមានថវិកាកំណត់ក៏ត្រូវការជំនួយផងដែរនៅពេលដែលពួកគេរងផលប៉ះពាល់ពីជំងឺរាតត្បាតនេះ៕

*ដោយ មុំ ចិន្តា*

*ប្រភព៖ Bangkor Post ចេញផ្សាយថ្ងៃ ២០ ខែមេសា ឆ្នាំ២០២១*

## សេដ្ឋកិច្ចសកល

### សេដ្ឋកិច្ចរបស់អាមេរិករំពឹងមានកំណើនខ្លាំងឡើងវិញ ប៉ុន្តែកំណើនការងារមានភាពយឺតយ៉ាវ



*ប្រភព៖ ការទទួលទានការអាហារពេលល្ងាចនៅខាងក្រៅផ្ទះកាលពីខែមេសា នៅសាន់ហ្វ្រាន់ស៊ីស្កូ៖ ការចំណាយរបស់អ្នកប្រើប្រាស់ និងសេដ្ឋកិច្ចងើបឡើងវិញលឿនជាងល្បឿននៃការជួលមនុស្សឱ្យធ្វើការ។ រូបភាព ៖ DAVID PAUL MORRIS / BLOOMBERG NEWS*

ចំណាយរបស់អ្នកប្រើប្រាស់នៅក្នុងវិស័យភោជនីយដ្ឋាន សណ្ឋាគារ និងសាឡននៅសហរដ្ឋអាមេរិក កំពុងតែចាប់ផ្តើមមានដំណើរការឡើងវិញ ដោយសារតែការរាតត្បាតនៃជំងឺកូវីដ-១៩ បានថមថយចុះ និងចំនួនមនុស្សដែលបានទទួលវ៉ាក់សាំងកាន់តែមានចំនួនច្រើនឡើង។ ប៉ុន្តែនិយោជកអាចនឹងមានការពិបាកនៅក្នុងការជួលកម្មករ-និយោជិតនៅក្នុងអំឡុងពេលប៉ុន្មានខែខាងមុខនេះ ដើម្បីរត់ឱ្យទាន់កំណើនសេដ្ឋកិច្ច ព្រោះការកើនឡើងនៃសកម្មភាពសេដ្ឋកិច្ចមានកំណើនលឿនជាងប្រាក់ឈ្នួល ជាពិសេសនៅក្នុងដំណាក់កាលដំបូងនៃការងើបឡើងវិញ។

យោងតាមការស្ទង់មតិដែលបានធ្វើឡើងដោយក្រុមសេដ្ឋកិច្ចវិទូរបស់ The Wall Street Journal សេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិកនៅក្នុងឆ្នាំនេះ អាចនឹងមានកំណើនក្នុងរង្វង់ ៦,៤% គិតដល់ត្រីមាសទី៤ ឆ្នាំ២០២១ ធៀបនឹងត្រីមាសទី៤ឆ្នាំ២០២០ ។ បើធៀបទៅនឹងស្ថានភាពសេដ្ឋកិច្ចមុនពេលមានវិបត្តិជំងឺកូវីដ-១៩ កំណើននេះខ្ពស់ជាងត្រីមាសទី៤ ឆ្នាំ២០១៩ ជិត៤%។

ក្រុមសេដ្ឋកិច្ចវិទូរំពឹងទុកទៀតថា និយោជកអាចនឹងបង្កើតការងារបន្ថែមទៀតចំនួន ៧,១លានកន្លែង ក្នុងរយៈពេល ១២ខែ រហូតដល់ ខែធ្នូ ឆ្នាំ២០២១ ពោលគឺកើនបាន ៥% ដែលទាបជាងត្រីមាសទី៤ ឆ្នាំ២០១៩ ចំនួន ១,៦%។

សេដ្ឋកិច្ចវិទូបានពន្យល់ថា កំណើនការងារយឺតយ៉ាវនឹងទាញផ.ស.ស.របស់សហរដ្ឋអាមេរិកឱ្យមានកំណើនយឺត ដោយសារមូលហេតុពីរគឺ៖ ទី១ ក្រុមហ៊ុនជាច្រើននៅតែមានការស្ទាក់ស្ទើរនៅក្នុងការជួលកម្មករ-បុគ្គលិក ពីព្រោះពួកគេនៅមិនទាន់ជឿទុកចិត្តបានថា

ការកើនឡើងនៃតម្រូវការរបស់អតិថិជនមានភាពស្ថិតស្ថេរ ឬយ៉ាងណា ព្រោះគេមិនដឹងថា កូវីដ-១៩ នឹងបញ្ចប់ទៅនៅពេលណានោះទេ។ បើទោះបីជា ចំនួនអ្នកដែលទទួលបានវ៉ាក់សាំងមានការកើនឡើងក្តី ប៉ុន្តែករណីឆ្លងនៅតែបន្តកើនឡើងឥតឈប់ ហើយការរឹតបន្តឹងលើសកម្មភាពអាជីវកម្មនៅតែបន្តកើតមាន ខណៈដែលផ្នែកជាច្រើននៃប្រទេសនៅតែបន្តរងគ្រោះដោយសារជំងឺកូវីដ-១៩។ លើសពីនោះ ពួកគេយល់ថា អាជីវកម្មធ្វើដំណើរប្រហែលជាមិនអាចវិលត្រឡប់ទៅរកសភាពដើមវិញបានទេ។ ទី២-នៅក្នុងអំលុងកូវីដ-១៩ កម្មករ-និយោជិតរាប់លាននាក់បានបាត់បង់ការងារដោយសារជំងឺរាតត្បាតនេះ ដូចនេះពួកគេត្រូវការពេលវេលាដើម្បីស្វែងរកការងារ។

គួររំលឹកថា ចំនួនប្រជាពលរដ្ឋនៅសហរដ្ឋអាមេរិកដែលមានអាយុចាប់ពី២៥ឆ្នាំ ដល់ ៥៤ឆ្នាំ ដែលមានការងារធ្វើ ឬកំពុងតែស្វែងរកការងារធ្វើធ្លាក់ចុះពី ៨២,៩% កាលពីខែកុម្ភៈ ឆ្នាំ២០២០ មកនៅត្រឹម ៨១,៣% នៅក្នុងខែមីនាឆ្នាំ២០២១ ដែលបានថយចុះចំនួន ១,៩លាននាក់។ ការធ្លាក់ចុះនេះ កើតឡើងដោយសារប្រជាពលរដ្ឋភាគច្រើនចាកចេញពីកម្លាំងពលកម្ម ឈប់ធ្វើការដើម្បីមើលថែកូននៅផ្ទះក្នុងអំឡុងពេលបិទសាលារៀន។ ចំណែកឯ ពលរដ្ឋមួយចំនួនទៀត មិនហ៊ានចេញទៅក្រៅស្វែងរកការងារធ្វើ ព្រោះតែខ្លាចជំងឺកូវ៉ីណា។ លើសពីនោះ ដោយសារការអនុវត្តគោលនយោបាយផ្តល់ប្រាក់ឧបត្ថម្ភចំនួន ៣០០ដុល្លារក្នុងមួយសប្តាហ៍សម្រាប់អ្នកដែលអត់ការងារធ្វើ នៅក្នុងការអនុម័តទឹកប្រាក់សរុបចំនួន ១,៩ទ្រីលានដុល្លារ ដែលជាហេតុផលមួយដែលនាំឱ្យពលរដ្ឋមួយចំនួនលែងស្វែងរកការងារ។

ការធ្លាក់ចុះយ៉ាងខ្លាំងនៃការចូលរួមចំណែករបស់កម្លាំងពលកម្មមិនបង្ហាញពីសញ្ញានៃការងើបឡើងវិញយ៉ាងឆាប់រហ័សទេ។ ទោះបីជាបច្ចុប្បន្ននេះ តម្រូវការការងារមានកម្រិតច្រើនជាងមុនពេលមានវិបត្តិកូវីដ-១៩ ប៉ុន្តែ បើយោងតាមទិន្នន័យស្វែងរកការងារធ្វើតាមអនឡាញ ចំនួនអ្នកស្វែងរកការងារធ្វើនៅសហរដ្ឋអាមេរិកធ្លាក់ចុះយ៉ាងខ្លាំង។ លោក Daniel Zhao សេដ្ឋកិច្ចវិទូជាន់ខ្ពស់របស់ Glassdoor បាននិយាយថា "វាគឺជាការដែលគួរឱ្យព្រួយបារម្ភ ដែលការចូលរួមចំណែករបស់កម្លាំងពលកម្មនៅសហរដ្ឋអាមេរិកមិនអាចត្រឡប់មកសភាពដើមវិញលឿន បើទោះបីជា ការរាតត្បាតនៃជំងឺកូវីដ-១៩ ត្រូវបានបញ្ចប់ទៅហើយក្តី"។

ដូចនេះ ភាពអត់ការងារធ្វើរយៈពេលវែង គឺជាឧបសគ្គមួយ។ គួររំលឹកថា កាលពីខែកុម្ភៈ ឆ្នាំ២០២០ ចំនួនអ្នកអត់ការងារធ្វើនៅសហរដ្ឋអាមេរិកមានចំនួន ១,១លាននាក់ និងកើនឡើងដល់ទៅ ៤,២លាននាក់ នៅក្នុងខែមីនា ឆ្នាំ២០២១។ លោក Jay Bryson ប្រធានសេដ្ឋវិទូរបស់ Wells Fargo's Corporate បាននិយាយថា "ប្រសិនបើកម្មករ-និយោជិតអត់ការងារធ្វើក្នុងរយៈពេលយូរ នោះជំនាញពួកគេនឹងក្រិន ដែលអាចនឹងនាំឱ្យពួកគេពិបាកនៅក្នុងការស្វែងរកការងារធ្វើម្តងទៀត"។

ជាលទ្ធផលជាបណ្តោះអាសន្ន បញ្ហានេះធ្វើឱ្យអ្នកប្រើប្រាស់មិនសូវមានទំនុកចិត្ត ដរាបណាតម្រូវការ និង

ការផ្តត់ផ្គត់មិនមានតុល្យភាពគ្នា។ ឧទាហរណ៍៖ ដើម្បីទទួលអតិថិជនឱ្យបានច្រើន ហាងសាឡនតម្រូវឱ្យជាងកាត់សក់ធ្វើការថែមម៉ោង ចំណែកឯវិស័យភោជនីយដ្ឋានវិញ ដើម្បីទាញកម្មករឱ្យមកធ្វើការ ពួកគេបង្កើនប្រាក់ឈ្នួល ហេតុនេះ ពួកគេបង្កើនថ្លៃមុខម្ហូបជាដើម។ល។ លោក Bryson បានបន្ថែមថា នៅក្នុងអំលុងពេលប៉ុន្មានខែខាងមុខទៀត គេនឹងឃើញថា តម្រូវការនឹងមានការកើនឡើងខ្លាំង ហើយសំពាធនៃប្រាក់ឈ្នួល ក៏នឹងកើនឡើងទៅតាមនោះដែរ៕

*ដោយ វង្ស ច័ន្ទស្មើដារា*

*ប្រភព៖ គេហទំព័រ The Wall Street Journal, ចេញផ្សាយថ្ងៃទី ១៨ ខែមេសា ឆ្នាំ២០២១*

## វិបត្តិជំងឺកូវីដ-១៩ នឹងបន្សល់ទុកនូវស្លាកស្នាមយ៉ាងជ្រាលជ្រៅនៅក្នុងសេដ្ឋកិច្ចពិភពលោក ទោះបីជាសេដ្ឋកិច្ចងើបឡើងវិញក៏ដោយ



*ប្រភព៖ BLOOMBERG NEWS ២០២១*

ទោះបីជាជំនួយប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ មានទំហំដល់ទៅ ២៦ទ្រីលានដុល្លារ និងការទទួលបានការចាក់វ៉ាក់សាំងប្រឆាំងជំងឺកូវីដ-១៩ ដែលធ្វើឱ្យសេដ្ឋកិច្ចងើបឡើងវិញលឿនយ៉ាងណាក្តី ក៏ផលប៉ះពាល់ចំពោះវិស័យអប់រំ ភាពបាត់បង់ការងារ ទំហំបំណុលនៅក្នុងអំឡុងពេលជំងឺកូវីដ-១៩ និងវិសមភាពយេនឌ័រ ពូជសាសន៍ ភូមិសាស្រ្ត និងវិសមភាពរវាងមនុស្សពីមួយជំនាន់ទៅមួយជំនាន់កាន់តែរីកធំឡើង គឺជាស្លាកស្នាមមួយដ៏ជ្រាលជ្រៅ ដែលបានបន្សល់ទុកពីវិបត្តិជំងឺកូវីដ-១៩ ជាពិសេសនៅតាមបណ្តាប្រទេសក្រីក្រ។

លោក Vellore Arthi មកពីសាកលវិទ្យាល័យកាលីហ្វ័រញ៉ា ដែលបានឃ្លាំមើលផលប៉ះពាល់រយៈពេលវែងចំពោះសុខភាព និងសេដ្ឋកិច្ចដោយសារវិបត្តិនានាកន្លងមក បានមានប្រសាសន៍ថា "វាគឺជារឿងងាយស្រួលនៅពេលដែលយើងមានអារម្មណ៍ថា បានធូរស្បើយនៅពេលដែលអ្វីៗត្រឡប់មករកសភាពដើមវិញ ប៉ុន្តែផលប៉ះពាល់ជាច្រើន ដែលមាននៅក្នុងប្រវត្តិសាស្រ្តកន្លងមក បានបង្ហាញថា វិបត្តិនីមួយៗតែងតែបន្សល់ស្លាកស្នាមរបស់វាអស់រយៈពេលជាច្រើនទសវត្សរ៍ និងមិនងាយដោះស្រាយ" ។

ការធ្លាក់ចុះសេដ្ឋកិច្ចកាលពីឆ្នាំទៅ បានបង្ហាញពីសភាពធ្ងន់ធ្ងរលើសពីវិបត្តិសេដ្ឋកិច្ចសកល។ អង្គការពលកម្មអន្តរជាតិ (ILO) បានឱ្យដឹងថា មនុស្សប្រមាណជា ២៥៥លាននាក់ បានបាត់បង់ការងារពេញម៉ោងដោយសារតែជំងឺកូវីដ-១៩។ ក្រុមអ្នកស្រាវជ្រាវរបស់ Pew Research Centre បានបញ្ជាក់ថា នេះគឺជាការធ្លាក់ចុះនៃប្រទេសសេដ្ឋកិច្ចកម្រិតមធ្យមនៅក្នុងពិភពលោកជាលើកដំបូង ដែលមិនធ្លាប់មានចាប់តាំងពីទសវត្សរ៍ ១៩៩០ មក។

ជាក់ស្តែង Oxford Economic Ltd បានបង្ហាញថា សេដ្ឋកិច្ចរបស់ហ្វីលីពីន ប៉េរ៉ូ កូឡុំប៊ី និងអេស្ប៉ាញ រងគ្រោះខ្លាំងជាងគេ និងអាចបន្សល់ទុកនូវស្លាកស្នាមដ៏ជ្រាលជ្រៅក្នុងរយៈពេលវែង។ ខណៈដែលសេដ្ឋកិច្ចរបស់ប្រទេសអូស្ត្រាលី ជប៉ុន ណ័រវេ៉ អាឡឺម៉ង់ និងស៊ុយអ៊ែតមានភាពល្អប្រសើរជាងគេ។

អ្នកស្រី Carmen Reinhart ប្រធានសេដ្ឋវិទូរបស់ធនាគារពិភពលោកបាននិយាយថា ការងើបឡើងវិញរបស់សេដ្ឋកិច្ចត្រូវការពេលវេលាយូរ និងសេដ្ឋកិច្ចរបស់ប្រទេសជាច្រើននៅក្នុងពិភពលោកពិបាកត្រលប់ទៅរកសភាពដើមវិញណាស់ ព្រោះផលប៉ះពាល់លើប្រទេសទាំងអស់នៅក្នុងពិភពលោកមិនដូចគ្នា។

ស្ថាប័នរូបិយវត្ថុអន្តរជាតិ (IMF) បានបង្ហាញថា ប្រទេសដែលមានសេដ្ឋកិច្ចរឹងមាំទទួលរងផលប៉ះពាល់តិចតួច។ ប៉ុន្តែ ប្រទេសដែលមានសេដ្ឋកិច្ចកំពុងរីកលូតលាស់ និងប្រទេសមានប្រាក់ចំណូលទាបទទួលរងផលប៉ះពាល់ខ្លាំងជាងគេ ផ្ទុយពីវិបត្តិហិរញ្ញវត្ថុឆ្នាំ២០០៩។ ផ.ស.ស. របស់សហរដ្ឋអាមេរិកនៅឆ្នាំក្រោយអាចនឹងមានកំណើនខ្លាំងជាងការព្យាករណ៍មុនពេលមានវិបត្តិជំងឺកូវីដ-១៩។ យោងតាមការព្យាករណ៍របស់ IMF សេដ្ឋកិច្ចរបស់ប្រទេសមហាអំណាច ដែលជាប់ចំណាត់ថ្នាក់លេខមួយក្នុងពិភពលោកនេះ ទទួលរងគ្រោះ និងបន្សល់ទុកស្លាកស្នាមតិចតួច។

ធនាគារពិភពលោកបានធ្វើការព្រមានកាលពីខែមករា នៅក្នុងរបាយការណ៍របស់ខ្លួនយ៉ាងដូច្នេះថា ប្រសិនបើមិនមានវិធានការកែតម្រូវ នោះកំណើនសេដ្ឋកិច្ចរបស់ពិភពលោក អាចនឹងរងគ្រោះអស់រយៈពេលពេញមួយទសវត្សរ៍។ ការព្យាករណ៍កំណើនសេដ្ឋកិច្ចរបស់ពិភពលោកសម្រាប់ឆ្នាំ២០២៥ អាចនឹងមានកំណើនទាបជាងនិន្នាការសេដ្ឋកិច្ចដែលបានព្យាករណ៍មុនពេលមានវិបត្តិជំងឺកូវីដ-១៩ ប្រមាណ៥%។ រីឯ កំណើន ដែលអត្រាអតិផរណាកើនខ្ពស់ អាចនឹងធ្លាក់ចុះទាបជាង ២% នៅក្នុងទសវត្សរ៍ខាងមុខ ដែលចាប់តាំងពីទសវត្សរ៍មុនរហូតមកដល់ទសវត្សរ៍ទី២០នេះ កំណើនបានធ្លាក់ចុះពី ៣,៥% មកនៅត្រឹម ២,៥%។

ទោះយ៉ាងណា អ្នកជំនាញបានលើកទឹកចិត្តថា ប្រសិនបើការអនុវត្តគោលនយោបាយបោះជំហានបានត្រឹមត្រូវ នោះសេដ្ឋកិច្ចពិភពលោក នឹងមិនខាតបង់រហូតដល់មួយទសវត្សរ៍ឡើយ។ ប៉ុន្តែ គេត្រូវយកចិត្តទុកដាក់ពង្រឹងមូលដ្ឋានគ្រឹះសេដ្ឋកិច្ចដែលរងគ្រោះខ្លាំង និងត្រូវពង្រឹងជំនាញកម្មករ-និយោជិត។ លើសពីនោះ រដ្ឋគួរតែបង្កើតគោលនយោបាយលើកទឹកចិត្តដល់អាជីវកម្មនៅក្នុងការវិនិយោគ និងការបង្កើតថ្មី ជាពិសេស វិធានការគ្រប់គ្រងអាកាសធាតុផងដែរ។ ពេលដើម្បីជំរុញឱ្យសេដ្ឋកិច្ចឆាប់ងើបឡើងវិញ រដ្ឋទាំងអស់ត្រូវតែដាក់ចេញគោលនយោបាយចម្រុះរួមគ្នា។

ទោះយ៉ាងណា បញ្ហាចោទមួយទៀតនៅពេលនេះ គឺទំនុកចិត្តរបស់អ្នកប្រើប្រាស់ និងនិន្នាការនៃការចំណាយកំពុងតែមានការប្រឈម ដោយសារមនុស្សមានកង្វល់ចំពោះបញ្ហាសុខភាព និងដោយសារតែពួកគេមានវិបត្តិការងារ ដែលអាចបន្សល់ទុកនូវផលប៉ះពាល់ដូចវិបត្តិ

សេដ្ឋកិច្ចកាលពីឆ្នាំ១៩៣០ ដែរ បើទោះបីជា មនុស្សនាំគ្នាសន្សំសំចៃលុយទុកកាលពីឆ្នាំកន្លងទៅនេះក៏ដោយ។

ប្រវត្តិសាស្ត្របានបង្ហាញថា ជាទូទៅប្រាំឆ្នាំក្រោយ បន្ទាប់ពីមានវិបត្តិ ការរំពឹងទុកនៃកំណើនសេដ្ឋកិច្ចនៅក្នុងរយៈពេលវែង តែងតែទាបជាងការព្យាករណ៍កំណើនសេដ្ឋកិច្ចមុនពេលមានវិបត្តិប្រហែលជា ១,៥ពិន្ទុភាគរយ នេះបើយោងតាមការអះអាងរបស់ធនាគារពិភពលោក។

បញ្ហាមួយទៀត ដើម្បីការពារមនុស្សពីការឆ្លងរីករាលដាលជំងឺកូវីដ-១៩ ប្រទេសមួយចំនួនចាប់ផ្ដើមប្រើប្រាស់មនុស្សយន្តជំនួសកម្លាំងពលកម្ម ខណៈដែលពិភពលោករំពឹងទុកថា នៅពេលដែលសេដ្ឋកិច្ចងើបឡើងវិញ មនុស្សនឹងមានការងារធ្វើច្រើន។ គួរបញ្ជាក់ថា នៅឆ្នាំ២០៣០ មានមនុស្សប្រហែលជាង ១០០លាននាក់ នៅតាមបណ្ដាប្រទេសដែលមានសេដ្ឋកិច្ចធំៗ អាចនឹងត្រូវប្ដូរការងារ។ អ្នកដែលទទួលរងគ្រោះខ្លាំងជាងគេ គឺស្ត្រី កម្មករដែលមានចំណេះដឹងទាប អ្នកនៅវ័យក្មេង និងក្រុមជនជាតិភាគតិច។ Eric Robertsen ប្រធានផ្នែកស្រាវជ្រាវសកលរបស់ Standard Chartered Plc បានមានប្រសាសន៍ថា ការងារជាច្រើននឹងត្រូវបាត់បង់ជារៀងរហូត។ ដោយឡែក ចំពោះការងារមួយចំនួន ដែលមិនបាត់បង់ អាចនឹងផ្លាស់ប្ដូរនិន្នាការ ដែលអាចនឹងនាំឱ្យមានផលប៉ះពាល់ចំពោះប្រាក់ឈ្នួលរបស់កម្មករ-និយោជិត។

លើសពីនោះ ផលប៉ះពាល់ក្នុងរយៈពេលវែងចំពោះការអភិវឌ្ឍធនធានមនុស្ស ក៏ជាកត្តាប្រឈមមួយទៀតដែរ ដោយសារកុមារ និងសិស្សនិស្សិតមិនអាចទៅសាលាព្រោះតែការរីករាលដាលកូវីដ-១៩។ យោងតាមអង្គការសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD)[1] សិស្សថ្នាក់ទី១ ដល់ ថ្នាក់ទី១២ ដែលទទួលរងគ្រោះដោយសារវិបត្តិនេះ អាចនឹងរកប្រាក់ចំណូលបានទាបជាង ៣% ពេញមួយជីវិតធៀបនឹងករណីដែលគ្មានវិបត្តិ ជាពិសេសសិស្សដែលរស់នៅក្នុងគ្រួសារក្រីក្រ និងជាជនជាតិភាគតិច។ ការបិទសាលាត្រឹមតែ ១ភាគ៣ នៃឆ្នាំសិក្សារបស់សិស្ស គិតចាប់ពីការរាតត្បាតនៃជំងឺ អាចធ្វើឱ្យប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចរបស់ប្រទេសរហូតដល់រយៈពេលដែលនៅសេសសល់ក្នុងមួយសតវត្សរ៍នេះ ។

បញ្ហាចោទមួយវិញទៀត យោងតាមវិទ្យាស្ថានហិរញ្ញវត្ថុអន្តរជាតិនៅក្នុងឆ្នាំ២០២០ ពិភពលោកបានខ្ចីប្រាក់ចំនួន ២៤ទ្រីលានដុល្លារ បន្ថែមទៀត នាំឱ្យបំណុលសរុបកើនឡើងដល់ ២៨១ទ្រីលានដុល្លារ ដែលអាចនឹងនាំឱ្យមានវិបត្តិបំណុល។ ប៉ុន្តែបើទោះបីជាគ្មានវិបត្តិបំណុលក៏ដោយ ក៏ការកើនឡើងនៃអត្រាការប្រាក់នឹងធ្វើឲ្យរដ្ឋាភិបាល និងឯកជនចាប់ផ្ដើមមានសម្ពាធ។

ទន្ទឹមនឹងនេះ គួរបញ្ជាក់ដែរថា ការងារនៅក្នុងពិភពលោកអាចត្រូវបានត្រឡប់មករកភាពប្រក្រតីវិញលឿន

[1] The Organization for Economic Co-operation and Development.

បន្ទាប់ពីវិបត្តិជំងឺកូវីដ-១៩ បើធៀបទៅនឹងបន្ទាប់ពីវិបត្តិហិរញ្ញវត្ថុឆ្នាំ២០០៨ប៉ុន្តែដោយឡែក សេដ្ឋកិច្ចពិភពលោកហាក់ដូចជានៅជាប់គាំង និងស្ថិតក្នុងស្ថានភាពទាបជាងមុនពេលមានវិបត្តិ៕

*ដោយ វង្ស ច័ន្ទស្មើដារា*

*ប្រភព៖ គេហទំព័រ Bloomberg, ចេញផ្សាយថ្ងៃទី១៨ ខែមេសា ឆ្នាំ ២០២១ និងបានធ្វើបច្ចុប្បន្នភាពថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមាន៖ សន្ទស្សន៍សេដ្ឋកិច្ចឈានមុខគេរបស់ប្រទេសជប៉ុន ការវិនិយោគផ្ទាល់ពីបរទេសនៅប្រទេសប្រេស៊ីល ប្រាក់ចំណេញឧស្សាហកម្មនៅប្រទេសចិន ទំនុកចិត្តអ្នកប្រើប្រាស់នៅប្រទេសអ៊ីតាលី ការបម្រែបម្រួលភាគហ៊ុនប្រេងឆៅ API របស់សហរដ្ឋអាមេរិក ទំនុកចិត្តអ្នកប្រើប្រាស់នៅប្រទេសបារាំង ឥណទានសម្រាប់ក្រុមហ៊ុន និងការផ្គត់ផ្គង់សាច់ប្រាក់ M៣ នៅតំបន់ចាយប្រាក់អឺរ៉ូ ឥណទានវិស័យឯកជនរបស់ប្រទេសអូស្ត្រាលី និងទុនបម្រុងអន្តរជាតិរបស់ប្រទេសឥណ្ឌា៕

ខាងក្រោម គឺជាប្រតិទិនដែលនាយកដ្ឋានស្រាវជ្រាវថវិកានឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

<u>ថ្ងៃចន្ទ ទី២៦ ខែមេសា ឆ្នាំ២០២១</u>

- សន្ទស្សន៍សេដ្ឋកិច្ចឈានមុខគេរបស់ប្រទេសជប៉ុន សម្រាប់ខែកុម្ភៈ
- ការវិនិយោគផ្ទាល់ពីបរទេសនៅប្រទេសប្រេស៊ីល សម្រាប់ខែមីនា

<u>ថ្ងៃអង្គារ ទី២៧ ខែមេសា ឆ្នាំ២០២១</u>

- ប្រាក់ចំណេញឧស្សាហកម្មនៅប្រទេសចិន ធៀបនឹងឆ្នាំមុន សម្រាប់ខែមីនា
- ទំនុកចិត្តអ្នកប្រើប្រាស់នៅប្រទេសអ៊ីតាលី សម្រាប់ខែមេសា

<u>ថ្ងៃពុធ ទី២៨ ខែមេសា ឆ្នាំ២០២១</u>

- ការបម្រែបម្រួលភាគហ៊ុនប្រេងឆៅ API របស់សហរដ្ឋអាមេរិក សម្រាប់ថ្ងៃទី២៣ ខែមេសា
- ទំនុកចិត្តអ្នកប្រើប្រាស់នៅប្រទេសបារាំង សម្រាប់ខែមេសា

<u>ថ្ងៃព្រហស្បតិ៍ ទី២៩ ខែមេសា ឆ្នាំ២០២១</u>

- ឥណទានសម្រាប់ក្រុមហ៊ុននៅតំបន់ចាយប្រាក់អឺរ៉ូ ធៀបនឹងឆ្នាំមុន សម្រាប់ខែមីនា
- ការផ្គត់ផ្គង់សាច់ប្រាក់ M៣ នៅតំបន់ចាយប្រាក់អឺរ៉ូ ធៀបនឹងឆ្នាំមុន សម្រាប់ខែមីនា

<u>ថ្ងៃសុក្រ ទី៣០ ខែមេសា ឆ្នាំ២០២១</u>

- ឥណទានវិស័យឯកជនរបស់ប្រទេសអូស្ត្រាលី ធៀបនឹងឆ្នាំមុន សម្រាប់ខែមីនា
- ទុនបម្រុងអន្តរជាតិរបស់ប្រទេសឥណ្ឌា សម្រាប់ថ្ងៃទី២៣ ខែមេសា